ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាផ្នែករដ្ឋប្បវេណី

សំណុំរឿងរដ្ឋប្បវេណី

លេខ : ២១៧

ចុះថ្ងៃទី ០៦ ខែសីហា ឆ្នាំ ១៩៩៩

សាលដីកា

លេខ : ១១៦

ចុះថ្ងៃទី ២៣ ខែតុលា ឆ្នាំ ២០០២

ក្នុងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០២ ដោយមានសមាសភាព ដូចតទៅ :

១-ឯកឧត្តម ឌិត មុន្តី ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
២-លោក ខៀវ មួន ចៅក្រម
៣-លោក ជីវ កេង ចៅក្រម
៤-លោក ប្រាក់ គឹមសាន ចៅក្រមរបាយការណ៍
៥-លោក ស៊ុន គឹម ចៅក្រម
៦-លោក គង់ ភីរុន ចៅក្រម
៧-លោក ឈឹម ស៊ីផល ចៅក្រម
៨-លោក សោម សិរីវឌ្ឍ ចៅក្រម
៩-លោក យស់ ហួរខឿន ចៅក្រម

ក្រឡាបញ្ជី លោកស្រី ទី រ៉ាវី

តំណាងមហាអយ្យការ លោក ឈួន ចាន់ថា ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ ១០២ ចុះថ្ងៃទី ០៩.៣.៩៩ នៃ សំណុំរឿងរដ្ឋប្បវេណីលេខ ៤៣ ចុះថ្ងៃទី ១៧.១២.៩៧ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ ចេង ជារ៉ាវុធ ភេទប្រុស អាយុ ៤៤ឆ្នាំ ជាតិខ្មែរ របររកស៊ី អ្នកយកពត៌មានវិទ្យុអប្សរា ទីលំនៅសព្វថ្ងៃផ្ទះលេខ ៥៩៤ ផ្លូវជាតិលេខ ២ ឃុំចាក់អង្រែ ស្រុកមានជ័យ ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ ចេង ថន "ស" ម្តាយឈ្មោះ ទាត់ ខាត់ "ស" ។

និង ចុងបណ្តឹងសាទុក្ខឈ្មោះ បេ គីឡាក់ ភេទប្រុស អាយុ៣៣ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃផ្ទះលេខ ៤៧ សង្កាត់ចតុមុខ ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ ។ ផ្ទេរសិទ្ធិអោយឈ្មោះ ភឹម ភន ភេទប្រុស អាយុ ៤២ឆ្នាំ ជាតិខ្មែរ របររកស៊ីលក់ដូរ ទីលំនៅសព្វថ្ងៃផ្ទះលេខ ៤០៤ ផ្លូវ ១៦៣ ក្រុម៤៨ សង្កាត់បឹងកេងកង៣ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ ភឹម កាន "រ" ម្តាយឈ្មោះ ម៉ិន ខែម "រ" ។ ដែលមានលោក ខឹន ពៅ ជាមេធាវី ។

កម្មវត្ថុបណ្តឹង : ប្តឹងទាមទារដី និង អោយរុះរបងចេញ

បានឃើញបណ្តឹងសាទុក្ខលើកទី២ លេខ ១៣០ ចុះថ្ងៃទី ០៩.៥.៩៥ របស់ឈ្មោះ ចេង ផារ៉ាវុធ ប្តឹងមិនសុខចិត្តពីសាលដីកាលេខ ១០២ ចុះថ្ងៃទី ០៩.៣.៩៥ របស់សាលាឧទ្ធរណ៍ លើចំនុច នៃសេចក្តីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ២១៧ ចុះថ្ងៃទី ០៦.៨.៩៥ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ១១.១១.៩៣ របស់ដើមចោទឈ្មោះ ប៉េ ឌីឡាក់ បញ្ជាក់ថា ខ្លួនប្តឹងសុំអោយ ចេង ផារ៉ាវុធ រុះរើរបងចេញ ពីដីឡូតិ៍របស់ខ្លួន ដោយហេតុថា ខ្លួនមានដីឡូតិ៍លេខ ៥០៩ និង ៥៩៤ ស្ថិតនៅផ្លូវជាតិលេខ ០២ ខ័ណ្ឌមានជ័យ មានវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ៦១៤១ ចុះថ្ងៃទី ១២.១២.៩១ ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ៩.៨.៩៤ របស់ដើមចោទឈ្មោះ ចេងផារ៉ាវុធ ប្តឹងមន្ទីរឧស្សាហកម្មរាជធានី និង ឈ្មោះ ម៉ែន សុផល ដែលឃុបឃិតធ្វើប្លង់ដី រឹបអូសយកដីមួយចំណែក នៃដីឡូតិ៍លេខ ៥៩៤ បំពានលើកម្មសិទ្ធិរបស់ខ្លួន ។ ដីទំនាស់នេះ ខ្លួនកាន់កាប់តាំងពីឆ្នាំ ១៩៧៩ ដោយមានដាំដំណាំ លុះដល់ឆ្នាំ ១៩៨២ រដ្ឋរៀបប្លង់នៅលើដីនេះ ខ្លួនមិនតវ៉ាដោយជាប្រយោជន៍ជាតិ ក្រោយមកនៅឆ្នាំ ១៩៩១ មន្ទីរឧស្សាហកម្មរដ្ឋ លួចលក់ដីនេះ អោយឯកជនឈ្មោះ ម៉ែន សុផល ដោយគ្មានការយល់ព្រម ពីប្រជាជនឡើយ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ៨១ "ក" ចុះថ្ងៃទី ៣១.៥.៩៥ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងចុះថ្ងៃទី ១១.១១.៩៣ របស់ដើមចោទឈ្មោះប៉េឌីឡាក់ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-ទទួលលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី ១១.១១.៩៣ របស់ឈ្មោះ ប៉េ ឌីឡាក់ អោយឈ្មោះ ភិន ភន ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

៣-បង្គាប់អោយឈ្មោះ ចេងផារ៉ាវុធ រុះរើរបង និង សំណង់គ្មានច្បាប់ ចេញពីដីឡូតិ៍លេខ ៥៩៤ ផ្លូវជាតិលេខ ២ សង្កាត់ចាក់អង្រែក្រោម ស្រុកមានជ័យ ចាប់ពីពេលសាលក្រមនេះចូលជាស្ថាពរ ។

៤-បង្គាប់អោយឈ្មោះ ចេង ផារ៉ាវុធ បង់ប្រាក់ប្រដាប់ក្តី ៧.០០០៛ គឺ ពន្ធចុះបញ្ជីក្តី និង ពន្ធថ្លឹង ១.៨០០៛ រង្វាន់ក្រឡាបញ្ជីកាតទីបប្រាក់ ២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ ៥.០០០៛ សរុប ៧.០០០៛ ប្រាក់នេះកាត់យកពីប្រាក់ ដែលដើមចោទបានបង់ទុករួចស្រេចហើយ កាលបើហួសកំណត់ប្តឹងឧទ្ធរណ៍ បង្គាប់អោយចុងចម្លើយ បង់សងអោយដើមចោទវិញ ។

៥-សាលក្រមនេះ ជំនុំជំរះ ជាសាធារណៈ ចំពោះមុខគូក្តី ដោយសំរេច

បើកផ្លូវប្តឹង ឧទ្ធរណ៍រយៈពេល២ខែ ចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

បានឃើញសាលក្រមលេខ ៨០ "ក" ចុះថ្ងៃទី ៣១.៥.៩៥ របស់ តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារ នៃ សេចក្តីសំរេចដូចតទៅ :

១ -ទទួលពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ ចេង ផារ៉ាវុធ ទុកជាត្រឹមត្រូវតាមទំរង់ តែបដិសេធចោល ដោយផ្ទុយនឹងគតិច្បាប់ ។

២ -សំរេចរឹបអូសប្រាក់ប្រដាប់ក្តី ចំនួន ៧.០០០៛ ដែលដើមចោទបានបង់ទុក រួចស្រេច គឺពន្ធចុះបញ្ជីក្តី និង ពន្ធថ្លឹង ១.៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ ២.០០០៛ រង្វាន់សាក្សី ៣.០០០៛ សរុប ៧.០០០៛ ។

៣ -សាលក្រមនេះ ជំនុំជំរះ ជាសាធារណៈ ចំពោះមុខគូក្តី សំរេចបើកផ្លូវ ឧទ្ធរណ៍ រយៈពេល ២ខែ គិតចាប់ពីថ្ងៃ ប្រកាសសាលក្រមនេះតទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៥៩ ចុះថ្ងៃទី ២១.៦.៩៥ របស់ឈ្មោះចេងផារ៉ាវុធ ប្តឹងមិនសុខចិត្ត លើសេចក្តីសំរេច នៃសាលក្រមលេខ ៨០កនិង សាលក្រមលេខ ៨១កចុះថ្ងៃទី ៣១.៥.៩៥ របស់ តុលាការក្រុងភ្នំពេញទាំងមូល ។

បានឃើញសាលដីការបៀបលេខ ៧៩ស្ទួន ចុះថ្ងៃទី ១៦.៧.៩៦ របស់សាលា ឧទ្ធរណ៍ ដែលមាន ខ្លឹមសារ នៃ សេចក្តីសំរេចដូចតទៅ :

បញ្ចូលសំណុំរឿងលេខ ៥៦៩ ចុះថ្ងៃទី ០៧.៨.៩៤ និង លេខ ២១៣ ចុះថ្ងៃទី ២១.៣.៩៤ របស់តុលាការក្រុងភ្នំពេញ ទៅជាសំណុំរឿងក្តីតែមួយ ដែលមានឈ្មោះ បេ ឌីឡាក់ ជាដើមចោទ ឈ្មោះ ម៉ែន សុផល និង តំណាងមន្ទីរឧស្សាហកម្ម ជាតតិយជន ខាង បេ ឌីឡាក់ និង ចេង ផារ៉ាវុធ ជាចុងចម្លើយ ចាប់ពីពេលនេះតទៅ ។

បានឃើញសាលដីការបស់សាលាឧទ្ធរណ៍ លេខ ២៥៩ ចុះថ្ងៃទី ១៦.៧.៩៦ ដែលមានខ្លឹមសារ នៃ សេចក្តីសំរេចដូចតទៅ :

១ -ទទួលបណ្តឹងឧទ្ធរណ៍លេខ ៥៩ ចុះថ្ងៃទី ២១.៦.៩៥ របស់ឈ្មោះ ចេងផារ៉ាវុធ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹង គតិច្បាប់ ។

២ -តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ៨០ "ក" និង ៨១ "ក" ចុះថ្ងៃទី ៣១.៥.៩៥ របស់ តុលាការក្រុងភ្នំពេញ ទុកជាបានការពេញទាំងមូល ដោយសំរេចបន្ថែមថា ប្រគល់ ដីទំនាស់ឡូតិ៍លេខ ៥៩៤ ស្ថិតនៅផ្លូវជាតិលេខ ២ ឃុំចាក់អង្រែក្រោម ស្រុកមានជ័យ រាជធានីភ្នំពេញ ដែលឈ្មោះ បេ ឌីឡាក់ កំពុងកាន់កាប់ និង ប្រើប្រាស់អោយទៅឈ្មោះ នេះ កាន់កាប់ និង ប្រើប្រាស់ ជាកម្មសិទ្ធិស្របច្បាប់តទៅ ។

៣ -រឹបអូសប្រាក់ប្រដាប់ក្តី ទៅជាតសាលាឧទ្ធរណ៍ ដែលឈ្មោះ ចេង ផារ៉ាវុធ បានបង់រួចហើយ គឺពន្ធចុះបញ្ជីក្តី និង ពន្ធថ្លឹង [illegible].៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

៤៥០៛ ចំណាយលើកិច្ចប្រគល់ដីការកោះ ៥.០០០៛ និង ចំណាយលើការផ្ទាត់ តុលាការ ៨.០០០៛ សរុប ១៣.០០០៛ ។

កាលបើផុតកំណត់ប្តឹងសាទុក្ខ បង្គាប់អោយឈ្មោះ ចេង ផាន់រាំនុត បង់ពន្ធលមាមាត្រមួយភាគរយ លើតម្លៃដីទំនាស់ ៤៥.០០០ ដុល្លាអាមេរិក ប្រាក់ពន្ធនេះ ៨០ ភាគរយ ត្រូវបានជាប្រយោជន៍ជាតិ និង ២០ ភាគរយ ត្រូវបានជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ។

៤-សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ នារពេលសវនាការចំពោះមុខដើមចោទ និង ចុងបណ្តឹងឧទ្ធរណ៍ សំរេចបើកផ្លូវប្តឹងសាទុក្ខ រយៈពេល ២ខែ គិតចាប់ពីថ្ងៃនេះតទៅ ។

បានឃើញបណ្តឹងសាទុក្ខលេខ២២០ ចុះថ្ងៃទី ០៥.៩.៥៦ របស់ឈ្មោះ ចេង ផាន់រាំនុត ប្តឹងមិនសុខចិត្តលើសេចក្តីសំរេច នៃ សាលដីកាទាំងមូល ។

បានឃើញសាលដីការបស់ តុលាការកំពូលលេខ១៥៩១ ចុះថ្ងៃទី ២៨.៨.៥៧ ដែលមានខ្លឹមសារ នៃ សេចក្តីសំរេចដូចតទៅ :

១-ទទួលបណ្តឹងសាទុក្ខលេខ ២២០ ចុះថ្ងៃទី ០៥.៩.៥៦ របស់លោក ចេង ផាន់រាំនុត ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ២៥៩ ចុះថ្ងៃទី ១៦.៧.៥៦ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ០៨ ចុះថ្ងៃទី ១០.០១.៥៧ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះ ជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តី ដែលលោក ចេង ផាន់រាំនុត បានបង់ទុកនៅតុលាការកំពូល ចំនួន ១៩.០០០៛ គឺ :

-ពន្ធចុះបញ្ជីក្តី និង ពន្ធផ្សេង ចំនួន ៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់បញ្ជីប្រាក់ .

-ចំណាយក្នុងការប្រគល់ដីការកោះ ចំនួន ១៥.០០០៛ សរុប ១៩.០០០៛ ហើយ តម្រូវអោយលោក ចេ គីឡាត់ សងប្រាក់ចំនួន ១៩.០០០៛ នេះទៅលោក ចេង ផាន់រាំនុត វិញ ។

៥-សាលដីកានេះ ប្រកាសនាយវនាការជាសាធារណៈ នៅថ្ងៃទី០៤.៩.៥៧ ។

បានឃើញសាលដីការបស់សាលាឧទ្ធរណ៍លេខ ៣៨៨ ចុះថ្ងៃទី ០៩.៧.៥៨ ដែលមានខ្លឹមសារ នៃ សេចក្តីសំរេចដូចតទៅ :

១-ទទួលជំនុំជំរះឡើងវិញនូវរឿងរដ្ឋប្បវេណីលេខ ៤៣ ចុះថ្ងៃទី ១៧.១២.៩៧ របស់សាលាឧទ្ធរណ៍ តាមអំណាចសាលដីការដ្ឋប្បវេណីលេខ ១៥១ ចុះថ្ងៃទី ២៨.៨.៩៧ របស់តុលាការកំពូល ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ៨១ "ក" ចុះថ្ងៃទី ៣១.៥.៩៥ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការដដែល ។

៣-កាត់យកប្រាក់ប្រដាប់ក្តី ដាក់សាលាឧទ្ធរណ៍ ចំនួន ១៣.០០០៛ ដែលដើមបណ្តឹងបានបង់រួចហើយ គឺ ពន្ធចុះបញ្ជីក្តី និង ពន្ធថ្លឹង ២.៥៥០៛ រង្វាន់ក្រឡាបញ្ជីការទទួលប្រាក់ ៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ ៥.០០០៛ និង ណើការផ្ទាគរ តុលាការ ៥.០០០៛ ។

៤-សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ កំបាំងមុខគូក្តី បើកផ្លូវប្តឹងទាស់ និង សាទុក្ខ តាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់របស់ឈ្មោះ ចេង ផារ៉ាវុធ ចុះថ្ងៃទី ០៧.៨.៩៨ ប្តឹងមិនសុខចិត្ត លើសេចក្តីសំរេច នៃ សាលដីកាទាំងមូល ។

បានឃើញសាលដីការបស់សាលាឧទ្ធរណ៍លេខ ១០២ ចុះថ្ងៃទី ០៩.៣.៩៩ ដែលមានខ្លឹមសារ នៃ សេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងទាស់ ចុះថ្ងៃទី ០៧.៨.៩៨ របស់ឈ្មោះ ចេង ផារ៉ាវុធ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោល ដោយទាស់នឹង គតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណី កំបាំងមុខលេខ ៣៨៨ ចុះថ្ងៃទី ០៩.៧.៩៨ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល ។

៣-សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខចុងចម្លើយ ចេង ផារ៉ាវុធ កំបាំងមុខដើមចោទ បើកផ្លូវប្តឹងសាទុក្ខ តាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលើកទី២ លេខ ១៣០ ចុះថ្ងៃទី ០៤.៥.៩៩ របស់ឈ្មោះ ចេង ផារ៉ាវុធ ប្តឹងមិនសុខចិត្តលើសេចក្តីសំរេច នៃ សាលដីកាទាំងមូល ។

បានឃើញសាលដីការបៀប របស់ តុលាការកំពូល លេខ ១៤៨ ចុះថ្ងៃទី ០៣.៨.២០០០ ដែលមានខ្លឹមសារ នៃ សេចក្តីសំរេចដូចតទៅ :

១-ចាត់របៀប អោយទៅក្រុមប្រឹក្សា ចុះពិនិត្យភាពជាក់ស្តែង នៃ មូលដ្ឋាន ។

២-សាលដីកានេះ ជំនុំជំរះ នៅថ្ងៃទី ៣.៨.២០០០ និង ប្រកាសជាសាធារណៈ នៅថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០០ ។

បានស្ដាប់របាយការណ៍បន្ថែម របស់ចៅក្រមរបាយការណ៍

បានស្ដាប់សេចក្ដីសន្និដ្ឋាន របស់តំណាងមហាអយ្យការ អមតុលាការកំពូល ថា :

-បណ្ដឹងសាទុក្ខរបស់ចុងចម្លើយ ធ្វើរ ទៀង ស្ថិតក្នុងកំណត់ច្បាប់ គប្បីលើកយកមក ពិនិត្យ ពិចារណា ។

-សាលដីការបស់សាលាឧទ្ធរណ៍ ដែលសំរេចសេចក្ដីមកនេះ គឺ មានលក្ខណៈ ខុសឆ្គង ទៅ នឹង គតិច្បាប់ ។ ហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះ សំរេចតាមច្បាប់ ។

បានស្ដាប់ចម្លើយ របស់ឈ្មោះ ចេង ដារ៉ាវុធ ជាម្ចាស់បណ្ដឹងសាទុក្ខ នៅពេលជំនុំជំរះឡើយ ថា :

-ខ្លួនមិនបដិសេធការរុះរើរបងចេញនោះទេ ប៉ុន្តែប្លង់ទាំងពីរ ដែល ឈ្មោះ ម៉ែន សុផល យកលក់អោយ ចេ ឌីឡាក់ ជាប្លង់សេះហោះ មិន ត្រឹមត្រូវ តាមលក្ខណៈបច្ចេកទេសភូមិបាល គឺគេគូសបិតគ្នា គូរចូលដីខ្លួនអស់៥ម ហើយផ្ទះរបស់ខ្លួន ស្ថិតនៅក្នុងដីឡូតិ៍លេខ ៥៨៤ តែ ដាក់ក្នុងប្លង់ ថា នៅក្នុងដីឡូតិ៍លេខ ៥៨២ ។ ដីខ្លួនមានទទឹង ៣០ម តែ ដាក់ក្នុងប្លង់មានតែ២៥ម បាត់ដីខ្លួនអស់ ៥ម ។ ខ្លួន សុំសិទ្ធិប្រើប្រាស់ផ្លូវលំទទឹង ១,៥០ម ដើម្បីដាក់ទុយោទឹក និង ដើរចុះទៅទន្លេ ដើម្បីជាប្រយោជន៍ របស់គ្រួសារ ខ្លួន និង គ្រួសារដទៃទៀតដែលរស់នៅទីនោះ ។

មេធាវី របស់ដើមចោទ ធ្វើសេចក្ដីសន្និដ្ឋាន ថា :

-គ្រប់សាលាក្ដីទាំងអស់បញ្ជាក់ថា ដីឡូតិ៍លេខ ៥៨៤ ជាកម្មសិទ្ធិរបស់ដើមចោទ ដែលមានបណ្ណកម្មសិទ្ធិស្របច្បាប់ត្រឹមត្រូវ តែចុងចម្លើយគាត់ថាផ្ទះរបស់គាត់ស្ថិតក្នុងដីឡូតិ៍លេខ ៥៨៤ ដែរ គឺជាន់កម្មសិទ្ធិរបស់កូនក្ដីខ្លួន ។ តាមការចុះពិនិត្យ របស់ចៅក្រមប្រឹក្សា តុលាការកំពូល ក៏បញ្ជាក់ថា ផ្ទះរបស់ចុងចម្លើយស្ថិតនៅក្នុងដីឡូតិ៍លេខ ៥៨២ ដែរ ។ គំនូសព្រាងរបស់តុលាការកំពូលចុះទៅពិនិត្យ ដាក់ទទឹងដីឡូតិ៍លេខ ៥៨២ ដល់ទៅ៣០ម គឺតាមពិតដីនេះមានទទឹងតែ ២៥មទេ ដូច្នេះ ចូលដីកូនក្ដីខ្លួនអស់ ៥ម ។ ចំណែកផ្លូវដែលចុងចម្លើយគាត់ទាមទារនេះ ជាផ្លូវដែលបោះបង់ចោល មិនសូវដើរ និង ពុះដីកូនក្ដីខ្លួនជាពីរទៀត ដូច្នេះកូនក្ដីខ្លួនមិនសុខចិត្តទេ ។ បើសុំដាក់ទុយោបង្កប់ក្នុងដីបាន ។ សុំអោយចុងចម្លើយរុះរើរោងឡាន ដែលបានសង់ក្នុងដីរបស់កូនក្ដីខ្លួនចេញ ។

-ក្រោយពីបានស្ដាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្ដាប់ សេចក្ដីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ ចម្លើយ របស់លោក ចេង ដារ៉ាវុធ និង សេចក្តី សន្និដ្ឋាន របស់មេធាវី ដើមចោទ

-ក្រោយពីបាន ពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលើកទី២ លេខ ១៣០ ចុះថ្ងៃទី ០៩.៥.៩៥ របស់លោក ចេង ដារ៉ាវុធ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះ ដល់អង្គសេចក្តីបាន តាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាព របស់សាលាជំរះក្តី និង មាត្រា២២៦ នៃច្បាប់ស្តីពី នីតិវិធីព្រហ្មទណ្ឌ ។

-យល់ឃើញថា នាសវនាការនៅសាលាឧទ្ធរណ៍ លោក ចេង ដារ៉ាវុធ បានបោះបង់ការទាមទាររបស់លោក លើដីទំនាស់ដែលលោក ម៉ែន សុផល រឹបអូសមួយចំណែកធំ នៃដីឡូតិ៍លេខ ៥៩៤ និង ឃ្លាំង ប៉ុន្តែលោកនៅបន្តទាមទារយកផ្លូវ ទទឹង ២ម៉ែត្រកន្លះ រហូតដល់ទន្លេ សំរាប់ជាផ្លូវសាធារណៈ ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ សំរេចតម្កល់សាលក្រមរដ្ឋប្បវេណី លេខ ៨១ "ក" ចុះថ្ងៃទី ៣១.៥.៩៥ របស់ តុលាការក្រុងភ្នំពេញ ទុកជាបានការ នោះ គឺជាការភ័ន្តច្រឡំ ពីព្រោះសាលក្រមនេះ ត្រូវបានសាលាឧទ្ធរណ៍ តំកល់ទុកជា បានការ តាមអំណាចសាលដីការដ្ឋប្បវេណីកំបាំងមុខលេខ ៣៨៨ ចុះថ្ងៃទី ០៩.៧.៩៨ និង សាលដីកាលេខ ១០២ ចុះថ្ងៃទី ០៩.៣.៩៩ ដែលត្រូវបានតុលាការកំពូលសំរេចទុកជា មោឃៈ តាមអំណាចសាលដីការដ្ឋប្បវេណីលេខ ១៥១ ចុះថ្ងៃទី២៨.៨.៩៧ រួចមកហើយ ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចតម្កល់ សាលក្រមរដ្ឋប្បវេណី លេខ ៨១ "ក" ចុះថ្ងៃទី ៣១.៥.៩៥ របស់ តុលាការក្រុងភ្នំពេញ ដែលបង្គាប់អោយ ឈ្មោះ ចេង ដារ៉ាវុធ រុះរើរបង និង សំណង់គ្មានច្បាប់ចេញពីដីឡូតិ៍លេខ ៥៩៤ ដោយពុំបានពិចារណា និង សំរេចទុកផ្លូវ ចំរើសេរី ភាព ឡើងចុះទៅកំពង់ទឹក អោយ ឈ្មោះ ចេង ដារ៉ាវុធ ប្រើប្រាស់ គឺជាការពុំត្រឹមត្រូវទេ ពីព្រោះថា មានភស្តុតាង គ្រប់គ្រាន់បញ្ជាក់ថា តាំងពីដើមរៀងមក មានផ្លូវលំ ចុះ ទៅកំពង់ទឹក សំរាប់ជាសេរី ភាព អោយគ្រួសារ លោក ចេង ដារ៉ាវុធ និង គ្រួសារផ្សេងទៀត ដែលរស់នៅ ក្នុងដីឡូតិ៍លេខ ៥៩៤ ប្រើប្រាស់ដោយពិតប្រាកដ ។

-យល់ឃើញថា ការដែលលោក ចេង ដារ៉ាវុធ ទាមទារសុំបើកផ្លូវដើរ ត ទុយទឹក និង ដាក់លូបង្ហូរទឹក ចុះទៅមាត់ទន្លេ ដោយកាត់ទទឹងដីកម្មសិទ្ធិរបស់លោក បេធីឡាក់ នោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះសំណូមពរនេះ ធ្វើអោយដីឡូតិ៍ របស់ លោក បេ ធីឡាក់ និង ឃ្លាំងរបស់លោក ដាច់ពីគ្នា ដូច្នេះគប្បី សំរេចអោយបើកផ្លូវ

ត្រង់មួយបន្តពីផ្លូវចាស់ ពីមាត់ទន្លេ មកផ្លូវជាតិលេខ២ ដែលផ្លូវតម្រូវអោយបើកថ្មីនេះ មានបណ្តោយ ពីដីចំណីផ្លូវជាតិលេខ ២ ទៅទល់នឹងផ្លូវចាស់ប្រវែង ២៥,៥០ ម៉ែត្រ និង មានទទឹង ២ ម៉ែត្រ ដោយវាស់ចេញពីរបងផ្នែកខាងត្បូង នៃដីកម្មសិទ្ធិរបស់លោក បេធីទ្យាក់ ។

-យល់ឃើញថា លោក ភឹម ភន តំណាងអោយលោក បេ ធីទ្យាក់ បាន ធ្វើសារណា ការពាររឿងក្តី របស់ខ្លួន ជូនមក តុលាការកំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួម នាសវនាការនេះទេ មានតែមេធាវីរបស់លោកមកចូលរួម ដូច្នេះតុលាការកំពូល ជំនុំជំរះ កំបាំងមុខ ចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ១០២ ចុះថ្ងៃទី ០៩.៣.៨៩ របស់សាលាឧទ្ធរណ៍ ដែលសំរេចសេចក្តីមកនេះ មានការខុសឆ្គង ទាំងទំរង់ ទាំង គតិច្បាប់ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តី ចំពោះមុខលោក ចេង ដារ៉ាំងុន កំបាំងមុខ លោក បេ ធីទ្យាក់ ប៉ុន្តែចាត់ទុកជាចំពោះមុខ

១ -ទទួលបណ្តឹងសាទុក្ខលើកទី២ លេខ ១៣០ ចុះថ្ងៃទី ០៥.៥.៨៩ របស់ លោក ចេង ដារ៉ាំងុន ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២ -ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ១០២ ចុះថ្ងៃទី ០៩.៣.៨៩ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣ -បង្គាប់អោយលោក ចេង ដារ៉ាំងុន រុះរើសំណង់គ្មានច្បាប់របស់ ខ្លួនចេញ ពីដីឡូតិ៍លេខ ៥៩៤ ផ្លូវជាតិលេខ២ សង្កាត់ចាក់អង្រែក្រោម ស្រុកមានជ័យ ដែលជាកម្មសិទ្ធិរបស់លោក បេ ធីទ្យាក់ ។

៤ -បង្គាប់អោយលោក បេ ធីទ្យាក់ បើកផ្លូវត្រង់មួយ បន្តពីផ្លូវចាស់ ពីមាត់ទន្លេ សំដៅទៅផ្លូវជាតិលេខ ២ ដែលផ្លូវតម្រូវអោយបើកថ្មីនេះ មានបណ្តោយ ពី ដី ចំណីផ្លូវជាតិលេខ ២ ទៅដល់ផ្លូវចាស់ មានប្រវែង ២៥,៥០ម៉ែត្រ មានទទឹង ០២ម៉ែត្រ វាស់ចេញពីរបងផ្នែកខាងត្បូង នៃ ដីកម្មសិទ្ធិរបស់លោក បេ ធីទ្យាក់ ។

៥ -រឹបអូសប្រាក់ប្រដាប់ក្តី ចំនួន ១៩.០០០៛ ដែលលោកចេងដារ៉ាំងុន បានបង់រួចហើយគឺ :

-ពន្ធចុះបញ្ជីក្តី និង ពន្ធថ្លឹង ចំនួន ៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ ចំនួន ៨០០៛ សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ .

-ចំណាយលើកិច្ចប្រគល់ដីការកោះ ចំនួន ១៥.០០០៛ សរុប១៩.០០០៛

ហើយត្រូវអោយលោក ខេ ធីឡាក់ សងប្រាក់ចំនួន ១៥.០០០៛ នេះទៅលោកចេងផា រ៉ាវុធ វិញ ។

៦-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០២ ។